00236255

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

A190/I/8

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១១)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ៤ វិច្ឆិកា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / NOV / 2008
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

---

សាធារណៈ:

សេចក្តីសម្រេចលើពាក្យសុំឱ្យមានសវនាការជាសាធារណៈ: របស់លោក ខៀវ សំផន

---

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 04 / NOV / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

**សហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**

ខៀវ សំផន

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke STUZINSKY
យ៉ុង ផានិត
គីម ម៉េងឃី
Martine JACQUIN

**សហមេធាវីការពារក្តី**

សា សូវ៉ាន
Jacques VERGÉS

១. **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ("អវតក") ទទួលបាន "ពាក្យសុំឱ្យមានសវនាការជាសាធារណៈ ស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធការបកប្រែសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ("ប្តឹងឧទ្ធរណ៍")។ ពាក្យសុំនេះបានដាក់នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៧ ("ពាក្យសុំ")។

## I. ប្រវត្តិនីតិវិធី

២. នៅក្នុងពាក្យសុំនេះ, សហមេធាវីការពារក្តីសន្និដ្ឋានថា "សេចក្តីសម្រេចបដិសេធពាក្យសុំបកប្រែសំណុំរឿងព្រហ្មទណ្ឌរបស់ លោក ខៀវ សំផន បង្កឱ្យមានការរំលោភដ៏ធ្ងន់ធ្ងរទៅលើសិទ្ធិរបស់ក្រុមការពារក្តី។ ហេតុដូច្នេះ សវនាការនេះនឹងអាចឈានទៅដល់សេចក្តីសម្រេចមួយដែលបញ្ចប់នីតិវិធីនានា និងអាចបង្គាប់ឱ្យមានការដោះលែងលោក ខៀវ សំផន ឱ្យមានសេរីភាពឡើងវិញ។ ដូចដែលវិធាន ៧៧(៦) នៃវិធានផ្ទៃក្នុងបានចែងស្រាប់, សវនាការជាសាធារណៈនឹងមានលក្ខណៈសមស្របជាទីបំផុត។ ហេតុដូច្នេះ ដើម្បីធានានូវសិទ្ធិជាសារវន្តរបស់លោក ខៀវ សំផន ឱ្យមានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងជាសាធារណៈ ដូចដែលមានចែងនៅក្នុងមាត្រា ១៤.១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សហមេធាវីការពារក្តីពិចារណាឃើញថា វាគឺជាប្រយោជន៍ចំពោះការវិនិច្ឆ័យមួយដ៏ត្រឹមត្រូវចំពោះសំណុំរឿងនេះ ដែលសវនាការនេះត្រូវប្រព្រឹត្តទៅជាសាធារណៈ។"[១]

៣. នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨, សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានតបចំពោះបណ្តឹងឧទ្ធរណ៍នេះ ("សេចក្តីសន្និដ្ឋានតប")។ នៅក្នុងវាក្យខណ្ឌទី ៤ និង វាក្យខណ្ឌទី៥ នៃសេចក្តីសន្និដ្ឋានតបនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ពុំចាំបាច់តម្រូវឱ្យមានសវនាការដេញដោលឡើយ ហើយស្នើឱ្យអង្គបុរេជំនុំជម្រះសម្រេចលើសំណុំរឿង ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ។[២]

៤. នៅក្នុងសេចក្តីបង្គាប់ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨, អង្គបុរេជំនុំជម្រះបានអញ្ជើញសហមេធាវីការពារក្តីរបស់ជនត្រូវចោទ ឱ្យដាក់សារណាតបចំពោះវាក្យខណ្ឌទី ៤ និងវាក្យខណ្ឌទី ៥ នៃសេចក្តីសន្និដ្ឋានតប ក្នុងរយៈពេលប្រាំពីរ(៧)ថ្ងៃ។

---

[១] ពាក្យសុំឱ្យមានសវនាការជាសាធារណៈស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធការបកប្រែសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ A190/I/2 វាក្យខណ្ឌទី ១៩ និងវាក្យខណ្ឌ ២០។

[២] សេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ A190/I/4 វាក្យខណ្ឌទី ៥។

៥. នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៨ សហមេធាវីការពារក្តីបានដាក់ "សារណាតបស្តីពីភាពចាំបាច់ឱ្យមានសវនាការជាសាធារណៈ"("សារណាតប")។ នៅក្នុងសារណាតបនេះ, សហមេធាវីការពារក្តីសន្និដ្ឋានថា "អង្គបុរេជំនុំជម្រះគឺជាអង្គជំនុំជម្រះមួយដ៏សំខាន់នៃការជជែកពិភាក្សាគ្នាស្តីពីសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌។ ការជជែកពិភាក្សាដ៏មានសារៈសំខាន់បំផុតគឺទាក់ទងនឹងនីត្យានុកូលភាព និងភាពគួរជាទីទុកចិត្តនៃ អ.វ.ត.ក។ ដោយសារហេតុផលនេះហើយទើបក្រុមការពារក្តីបានស្នើឱ្យមានការជជែកពិភាក្សានេះប្រព្រឹត្តទៅនៅក្នុងសវនាការជាសាធារណៈ។[...][៣] ជាការពិតណាស់, វាមិនមានហេតុផលត្រឹមត្រូវណាមួយដែលតម្រូវឱ្យយកបណ្តឹងឧទ្ធរណ៍នេះមកសម្រេច ដោយមិនមានសវនាការដេញដោលឡើយ។ [...] ម្យ៉ាងវិញទៀត ស្ថានភាពរបស់លោក ខៀវ សំផន មានលក្ខណៈខុសប្លែកពីគេ ហើយបណ្តឹងឧទ្ធរណ៍របស់គាត់ អាចនាំដល់ការបញ្ចប់នីតិវិធី។ ដោយហេតុតែពាក្យបណ្តឹងនេះចោទសួរអំពីនីត្យានុកូលភាពរបស់ អ.វ.ត.ក ជាជាងអ្វីផ្សេងទៀតនោះ បណ្តឹងឧទ្ធរណ៍នេះទាមទារឱ្យមានសវនាការជាសាធារណៈ"។[៤]

## II. សេចក្តីពិចារណា

៦. នៅក្នុងវិធានច្បាប់ដែលពាក់ព័ន្ធ, វិធាន ៧៧ នៃវិធានផ្ទៃក្នុង(វ.២) ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ ចែងថា:

> ៣. (ក) ប្រធានអង្គបុរេជំនុំជម្រះ ត្រូវផ្ទៀងផ្ទាត់ថាសំណុំរឿងនោះ មានភាពពេញលេញ និងកំណត់កាលបរិច្ឆេទសវនាការ ។
>
> (ខ) បន្ទាប់ពីបានពិចារណាលើការយល់ឃើញរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចលើបណ្តឹងឧទ្ធរណ៍ ឬ ពាក្យសុំដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋាន ជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ។
>
> ៥. សវនាការរបស់អង្គបុរេជំនុំជម្រះត្រូវធ្វើឡើងជា*អសាធារណៈ* លើកលែងតែមានចែងផ្សេងក្នុងអនុវិធាន ៦។ [...]
>
> ៦. តាមសំណើរបស់ចៅក្រមណាម្នាក់ ឬរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចថា នីតិវិធីទាំងស្រុង ឬមួយផ្នែកនៃសវនាការត្រូវធ្វើឡើងជាសាធារណៈ ជាពិសេសនៅពេលដែលសំណុំរឿងនោះអាចត្រូវបានបញ្ចប់ ដោយសេចក្តីសម្រេចរបស់ខ្លួន ដូចជាពាក្យបណ្តឹងឧទ្ធរណ៍ ឬ ពាក្យសុំពាក់ព័ន្ធទៅនឹងបញ្ហាយុត្តាធិការ ឬ មូលហេតុដែលនាំឱ្យរលត់បណ្តឹងអាជ្ញា បើអង្គបុរេជំនុំជម្រះយល់ឃើញថាដើម្បីជាប្រយោជន៍យុត្តិធម៌ និងមិនធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬវិធានការការពាររបស់តុលាការ។

---

[៣] សារណាតបរបស់ក្រុមមេធាវីការពារក្តីស្តីពីភាពចាំបាច់ឱ្យមានសវនាការជាសាធារណៈ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៨ A190/I/7 វាក្យខណ្ឌទី 3។

[៤] សារណាតបរបស់ក្រុមមេធាវីការពារក្តីស្តីពីភាពចាំបាច់ឱ្យមានសវនាការជាសាធារណៈ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៨ A190/I/7 វាក្យខណ្ឌទី 5។

៧. អនុលោមតាមវិធាន ៧៧(៦)នៃវិធានផ្ទៃក្នុង, សវនាការ *ជាសាធារណៈ* មានលក្ខណៈសមស្របជាទីបំផុត ក្នុងករណីដែលសំណុំរឿងនេះអាចឈានទៅដល់ការបញ្ចប់នីតិវិធី ដោយសារអំណាចនៃសាលដីការបស់អង្គបុរេជំនុំជម្រះ។ ដោយសារតែវិធាននេះត្រូវបានគេបង្កើតឡើងជុំវិញការសន្មតមួយថា កាលបរិច្ឆេទបើកសវនាការត្រូវបានគេកំណត់, វិធាននេះក៏អាចយកមកប្រើប្រាស់ជាបទដ្ឋានណែនាំក្នុងការកំណត់ថាតើជាគោលការណ៍ ករណីណាខ្លះដែលចាំបាច់មានសវនាការពេញអង្គ។ សហមេធាវីការពារក្តីបានផ្តល់អំណះអំណាងនៅក្នុងបណ្តឹងឧទ្ធរណ៍, ពាក្យសុំ, និងសារណាតបរបស់ខ្លួនថា សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍អាចនាំដល់ការបញ្ចប់នីតិវិធី។ សហមេធាវីបានធ្វើសេចក្តីសន្និដ្ឋានតបអំពីទ្រឹស្តីនៃការរំលោភបំពានលើកិច្ចដំណើរការនីតិវិធី ហើយផ្តល់អំណះអំណាងថា ជនត្រូវចោទគួរត្រូវតុលាការដោះលែងឱ្យមានសេរីភាព ដើម្បីជាការប៉ះប៉ូវនៃការរំលោភសិទ្ធិទាំងឡាយរបស់គាត់។

៨. អង្គបុរេជំនុំជម្រះទទួលស្គាល់ថា មូលដ្ឋានចំបងមួយក្នុងចំណោមមូលដ្ឋាននានា ក្នុងការបើកសវនាការជាសាធារណៈ គឺដើម្បីឱ្យសាធារណៈជនមានលទ្ធភាពពិនិត្យលើភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី។ ទាំងបណ្តឹងឧទ្ធរណ៍ ទាំងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា ត្រូវបានបោះពុម្ពផ្សាយនៅលើគេហទំព័ររបស់ អ.វ.ត.ក ដើម្បីជាផលប្រយោជន៍យុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ដែលត្រូវបើកចំហបណ្តឹងឧទ្ធរណ៍ជាសាធារណៈ។ សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានលើកអំណះអំណាងថា ផលវិបាកដែលកើតចេញពីការវិភាគវិនិច្ឆ័យរបស់អង្គបុរេជំនុំជម្រះ ចំពោះអង្គសេចក្តីនៃបណ្តឹងនេះគឺថាបណ្តឹងឧទ្ធរណ៍នេះអាចនាំដល់ការបញ្ចប់នីតិវិធី ហើយជនត្រូវចោទគួរត្រូវដោះលែងឱ្យមានសេរីភាព។ ហេតុដូច្នេះ សាធារណៈជនមានផលប្រយោជន៍ចំពោះសវនាការពេញអង្គនេះផងដែរ។ អង្គបុរេជំនុំជម្រះពិចារណាទៀតថា ការរៀបចំសវនាការជាសាធារណៈនឹងទំនងជាមិនធ្វើឱ្យប៉ះពាល់ដល់ការសំងាត់នៃកិច្ចស៊ើបសួរឡើយ។

**ហេតុដូច្នេះអង្គបុរេជំនុំជម្រះ÷**

(១) **ទទួលយក** ពាក្យសុំឱ្យមានសវនាការជាសាធារណៈ។

(២) **កំណត់** ថ្ងៃសវនាការនៅថ្ងៃទី **៨ ខែធ្នូ ឆ្នាំ២០០៨** វេលាម៉ោង **៩:០០ ព្រឹក**។ និង

(៣) **អញ្ជើញ** ភាគីទាំងអស់ដែលពាក់ព័ន្ធនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ ឱ្យចូលរួមនៅក្នុងសវនាការនេះ ដូចដែលបានកំណត់។

ភ្នំពេញ, ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន**